**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៤៨១.....អពដ

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## អំពីកម្រិតការប្រាក់ទីផ្សារសម្រាប់ប្រាក់ខ្ចី ឆ្នាំ២០១៤

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១៨ នៃច្បាប់ស្តីពីសារពើពន្ធ ផ្នែកទី២.៥ និងផ្នែកទី៥.៩ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញលេខ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ និងយោងតាមសេចក្តីណែនាំអំពីការកំណត់ចំណាយការប្រាក់របស់សហគ្រាស លេខ១៥១អពដ. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារបានកំណត់អត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់ខ្ចីឆ្នាំ២០១៤ ចំនួន ១០.១៥% ក្នុងមួយឆ្នាំ។ អត្រាការប្រាក់នេះ បានមកពីការគណនាមធ្យមភាគនៃមធ្យមភាគអត្រាការប្រាក់ឱ្យខ្ចីរបស់ធនាគារពាណិជ្ជធំៗក្នុងស្រុកចំនួន ៨ (ប្រាំបី)។

អាស្រ័យហេតុនេះគ្រប់អង្គភាពពន្ធដារ និងគ្រប់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ចំពោះលទ្ធផលសារពើពន្ធសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៤ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**<u>ចម្លងជូន:</u>**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពពន្ធដារ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Collection by VCAT Professional Consultant

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh